## ការហាមកាត់សេចក្តីពីរដង (Double Jeopardy)

គោលការណ៍នេះ ជាភាសាឡាតាំង គឺ *ne bis in idem* ជាវិធានទំនៀមទម្លាប់ (Customary International law) ដែលហាមឃាត់ ការវិនិច្ឆ័យសេចក្តីឬផ្តន្ទាទោស លើបុគ្គលណាមួយ ជាលើកទី២ សម្រាប់ទង្វើ ឬបទល្មើសដដែល។ គោលការណ៍ នេះស្រដៀងនឹងគោលការណ៍អាជ្ញាអស់ជំនុំ (*res judicata*)។

គោលការណ៍នេះ ហាមឃាត់តែការកាត់សេចក្តីក្នុងយុត្តាធិការដដែល (same jurisdiction)។ ក្នុងន័យថា វាមិនអាចហាមការកាត់ទោសដោយតុលាការក្នុងប្រទេសផ្សេងទេ។ វាមិនហាមការកាត់ទោសលើបទល្មើសដូចគ្នា ប្រសិនបើបទល្មើសទាំងពីរ មានធាតុផ្សំខុសគ្នា (cumulative conviction)។ គោលការណ៍នេះ ក៏មិនហាមឃាត់ការកាត់ទោសនាពេលបន្ទាប់ ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិទេ។ ការកាត់សេចក្តីគ្មានយុត្តិធម៌ដោយតុលាការរដ្ឋ មិនរារាំងតុលាការអន្តរជាតិ ក្នុងការកាត់សេចក្តីជាលើកទី២ទេ។ តុលាការអន្តរជាតិ ដែលទទួលកាត់សេចក្តី អាចនឹងពិចារណាការកាត់សេចក្តីលើកមុន សម្រាប់បន្ថយទោស (មាត្រា៨.៣ នៃ ICTY) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 304-305)។

**ខ្លឹមសារបន្ថែម៖** ការវិនិច្ឆ័យលើបណ្តឹងឧទ្ធរណ៍ មិនមែនជាការសម្រេចសេចក្តីលើបទល្មើសតែមួយឡើងវិញទេ។ ដូចនេះ គោលការណ៍នេះមិនហាមទេដំណើរការនៅសាលាឧទ្ធរណ៍។ ក្នុងសំណុំរឿង ០០២ របស់ **អវតក** ដែលមានជនជាប់ចោទឈ្មោះ **អៀង សារី** អង្គជំនុំជម្រះសាលាដំបូង អះអាងថា ការកាត់ទោសលោក **អៀង សារី** ពីមុនក្នុងឆ្នាំ ១៩៧៩ មិនមានភាពយុត្តិធម៌ ហើយ **អវតក** ជាតុលាការអន្តរជាតិ ដូចនេះ ការកាត់សេចក្តីឡើងវិញ មិនបំពានគោលការណ៍ហាមឃាត់ការកាត់សេចក្តីពីរដងនេះទេ (Decision of Trial Chamber ECCC, E51/15)។